# ប្រវត្តិខ្មែរត្រូវយួនកាប់

នៅឆ្នាំ១៩៤៥ និង១៩៤៦ ការកាប់សម្លាប់គ្នារវាងយួនអាណានិគមនិងខ្មែរម្ចាស់ស្រុក បានកើតឡើងទូទាំងកម្ពុជាក្រោមឬអតីតកូសាំងស៊ិន។កាសាដែលយួនយៀកមិញ ស្រែកឃោសនាបំកន្ទុមតិជាតិនិងអន្តរជាតិ   នៅពេលសម្លាប់ខ្មែរក្រោមថា កាប់យួនៗ ទៅវិញ។

រឿងរ៉ាវនេះ យើងគេទាំងឡាយតែងបានឮដូនតាយើង និទានតៗគ្នាមក ពីសម័យមួយទៅសម័យមួយដូចនៅខេត្តព្រះត្រពាំង យួនហៅត្រាយឹញនៅចុងឆ្នាំ១៩៤៥ចូលដើមឆ្នាំ១៩៤៦ បណ្តាប្រុសៗខ្មែរក្រោមនៅស្រុកផ្អោដាច ដូចភូមិផ្សារត្រកួន រាជមល្ង បេកជ្រំ ណាងណើង កៀវ កាន់ស្មម ធ្លុកបណ្តោយ ទទឹង កំពង់ទូកចុងមិ-សជើង ត្បូង ដំបូកបី រកាចាស់ រកាថ្មី កោះស្វាយ ផ្អោរាំង ទឹកយប់  ត្រពាំងពើ។ល។     ប្រុសៗរាប់ពាន់នាក់ ត្រូវយួនយៀកមិញ  ចាប់ចងគ្រៀក សណ្តោងបន្តគ្នា ហើយបណ្តើរយកទៅប្រានទម្លាក់ព្រែកកំពង់ខ្ទឹង ស្លាប់អស់គ្មានសល់។

នៅខេត្តឃ្លាំង ពលលាវ និងទឹកខ្មៅវិញ ខ្មែរត្រូវយួនចាប់ដុតទាំងរស់ រាប់ពាន់នាក់ ទាំងអស់មាន៩ជម្រុកស្រូវ គឺនៅ ដាំគីន ដាំយ៉ើយ ហោផុង យ៉ាវ៉ាយ ផ្អោអណ្តែត និងកោះមហត្ថ ។ល។

ខាងក្រោមនេះជារឿងនៅផ្អោអន្ទាក់ ស្រុកយ៉ាវ៉ាយ ខេត្តទឹកខ្មៅឆ្នាំ១៩៤៥(ស្រាវជ្រាវដោយលោកលីឈុន)ផ្អោអន្ទាក់ នៅចន្លោះភូមិសារិកា និងដីក្រហម គឺតាមបណ្តាយព្រែកយ៉ាវ៉ាយ  ចម្ងាយ២០គីឡូពីទីប្រជុំខេត្តទឹកខ្មៅ  សព្វថ្ងៃយួនបានដូរឈ្មោះ ហើយបញ្ចូលមកស្រុកដុងហាយ ខេត្តកាម៉ៅ។

ក្នុងអំឡុងខែបុស្ស ផល្គុនឆ្នាំ១៩៤៥ មេកងយួនយៀកមិញ ឈ្មោះហាយកៀង តាមសំដី លោកអ៊ឹំតាំងសេង នៅផ្អោអន្ទាក់គាត់មានអាយុ៩ឆ្នាំនៅឆ្នាំ១៩៤៥ បានឲ្យដឹងថា    ផ្អោអន្ទាក់មានវត្តមួយឈ្មោះវត្តថ្មីមានព្រះវិហារប្រក់ស្លឹក គ្រូសង្ក្រាជនាមហៀលអាយុប្រមាណ៣០ មានសិស្សគណចំនួន៦- ៧អង្គ មានពុទ្ធបរិស័ទមិនតិចជាង២០០គ្រួសារឡើយ។ គ្រូហៀលនិងញោមវត្តសាមនិងក្មេងប្រុសម្នាក់អាយុប្រហែល ៨-៩ឆ្នាំ ត្រូវពួកហាយកៀងធ្វើទារុណ្ណកម្ម ហើយសណ្តោងនឹងថ្មទាំងបីនាក់ រួចទម្លាក់ចោលក្នុងព្រែកយ៉ាវ៉ាយ។ ក្រោយមកប៉ុន្មានថ្ងៃ បរិស័ទបានឃើញព្រះកេសគ្រូហៀលអណ្តែតឃ្វីងឃ្វោងនៅក្នុងស្រះឈូកវត្ត

យ៉ាំរ៉ាយ តែដងខ្លួនមិនដឹងនៅទីណា ឯចីវរវិញ ត្រូវពួកហាកៀងបោះចោលរាយពាសពេញ នៅលើចុងឈើ។ នៅក្នុងវត្តយ៉ាំរ៉ាយ មានឃ្លាំងស្រូវរបស់ជប៉ុនចំនួនបួន ហើយពួកហាយកៀង ប្រមូលប្រុសៗកំពុងពេញកម្លាំង យកទៅញាត់ក្នុងឃ្លាំងនោះ ហើយពួកហាកៀង បានយកចំបើងមកដុតខ្មែរទាំងរស់អស់២ឃ្លាំង នៅ២ឃ្លាំងទៀត ខ្មែរបានទំលាយឃ្លាំងរំដោះខ្លួន ហើយប្រមូលកម្លាំងគ្នា វាយបកនឹងពួកហាកៀងវិញយ៉ាងអង់អាចក្លាហានជាទីបំផុត។

ឧបាយកលដែលពួកហាយកៀងបានធ្វើមកលើខ្មែរនោះគឺៈ

១-ចាប់ញាត់ក្នុងឃ្លាំងស្រូវ បង្អត់អាហារឲ្យវេញខ្សែពួរអំបោះចេក សំរាប់ចងខ្លួនឯង។

២-ចាប់ញាត់ក្នុងឃ្លាំងស្រូវ រួចគចំបើងដុតសម្លាប់ទាំងរស់។

៣-ឲ្យជីករណ្តៅសំរាប់កប់ខ្លួនឯង។

៤-បង្គាប់ឲ្យខ្មែរចងដៃគ្នាទៅវិញទៅមក រួចចាប់ទម្លាក់ក្នុងរណ្តៅ ហើយបង្គាប់ឲ្យខ្មែរដទៃទៀតកាយដីកប់ទាំងរស់។

៥-ចាប់ចងស្លាបសេកនិងខ្សែអំបោះចេក រួចច្រានទម្លាក់ក្នុងព្រែក។

៦-ចាប់ចងស្លាបសេក ដាក់ក្នុងទូកប៉ុកចាយ ហើយពន្លិចទូកឲ្យខ្មែរស្លាប់។

៧-ចាប់សណ្តោងនឹងថ្ម ហើយច្រានទម្លាក់ទឹកសម្លាប់ចោល។

៨-យកវល្លិអំបែងដែលមានជាតិពុល បង់ក្នុងស្រះ ហើយទម្លាក់ខ្មែរឲ្យស្លាប់ទាំងប្រុស-ស្រី។

៩-បាញ់សម្លាប់ដោយកាំភ្លើងបាញ់សត្វគ្រាប់ប្រែ។

១០-ធ្វើឲ្យខ្មែរស្លាប់ដោយជំងឺអាសន្នរោគ រាប់ពាន់នាក់ ដោយសារអាសោចនៃសាកសព។